ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ១៨៧...សសរ.....

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៧

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៧ ដែលមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| ១- ឯកឧត្ដម **ខឺ ច័ន្ទ្រផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |

| | |
|---|---|
| ៤- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៧- តំណាងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |
| ៨- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩- តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១១- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- តំណាងក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣- តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៤- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៥- តំណាងក្រសួងបរិស្ថាន | សមាជិក |
| ១៦- តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិក |
| ១៧- អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ១៨- អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៩- អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ២០- អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ២១- អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |
| ២២- អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ | សមាជិក |
| ២៣- អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ | សមាជិក |
| ២៤- អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ២៥- អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង | សមាជិក |
| ២៦- អភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់ | សមាជិក |
| ២៧- អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន | សមាជិក |
| ២៨- អភិបាល នៃគណៈអភិបាលខេត្តកោះកុង | សមាជិកា |
| ២៩- អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |

**ប្រការ ២.-**

គណៈកម្មការអន្តរក្រសួងខាងលើនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងបណ្តាខេត្តកម្ពុជា ដែលជាប់ព្រំដែនជាមួយប្រទេសថៃ ដើម្បីត្រៀមរៀបចំខ្លឹមសារនានាសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៧នេះឱ្យបានគ្រប់ជ្រុងជ្រោយ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- ពិភាក្សា និងសម្របសម្រួលជាមួយភាគីថៃ ដើម្បីរៀបចំខ្លឹមសារ និងកិច្ចការនានា ឱ្យបានសមស្របសម្រាប់កិច្ចប្រជុំលើកទី៧ នេះ
- រៀបចំគម្រោងថវិកាចំណាយនានាពាក់ព័ន្ធនឹងកិច្ចប្រជុំ
- ធានាឱ្យដំណើរការនៃកិច្ចប្រជុំប្រព្រឹត្តទៅមានភាពរលូន និងទទួលបានលទ្ធផលល្អប្រសើរ
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រមុខរាជរដ្ឋាភិបាល។

**ប្រការ ៣.-**

ក្នុងការអនុវត្តការងារ ប្រធានគណៈកម្មការអន្តរក្រសួងត្រូវសុំយោបល់ដឹកនាំផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អនុប្រធាន និងសមាជិកគណៈកម្មការអន្តរក្រសួង ត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ ៤.-**

គណៈកម្មការអន្តរក្រសួងអាចមានក្រុមការងារមួយចំនួនជាជំនួយការ ដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ។

ប្រធានគណៈកម្មការអន្តរក្រសួងអាចស្នើសុំមន្ត្រីនៃទីស្តីការក្រសួងមហាផ្ទៃ ឬមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងគណៈកម្មការអន្តរក្រសួង ឱ្យជួយការងារតាមការចាំបាច់ តាមការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីនៃក្រសួង ឬប្រធានស្ថាប័នពាក់ព័ន្ធទាំងនោះ។

**ប្រការ ៥.-**

ក្នុងការសម្របសម្រួលរៀបចំខ្លឹមសារនៃកិច្ចប្រជុំ គណៈកម្មការមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យចូលរួមតាមការចាំបាច់។

**ប្រការ ៦.-**

គណៈកម្មការអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងមហាផ្ទៃក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ ៧.-**

គណៈកម្មការអន្តរក្រសួងបញ្ចប់ការងាររបស់ខ្លួន បន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាលរួចរាល់ជាស្ថាពរ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានស្ថាប័នពាក់ព័ន្ធ និងសមាសភាពដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ